ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០១៥/១៤-ដុងឌូ ថេកស្តាយ (ខេមបូឌា)
កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៤

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ុង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ដុង ឌូ ថេកស្តាយ (ខេមបូឌា)**

អាសយដ្ឋាន ៖ ផ្លូវជាតិលេខ៣ សួនឧស្សាហកម្មវឌ្ឍនៈ២ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៧៧ ៥០៥ ០០០ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមផ្តល់ព័ត៌មានលំអិត ៖

- លោក Rocky Chhay Vice General Manager

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **សហព័ន្ធសហជីពការងារសេវាកម្មកម្ពុជា**
- **សហព័ន្ធសហជីពការពារកម្មករសំណង់កម្ពុជា**
- **សហព័ន្ធសហជីពស្មារតីកម្មករឯករាជ្យ**
- **សហព័ន្ធសហជីពសុវត្ថិភាពកម្មករ**
- **សហព័ន្ធសហជីពអភិវឌ្ឍន៍សិទ្ធិការងារ**
- **សហព័ន្ធសហជីពការងារកូនខ្មែរ**
- **សហព័ន្ធសហជីពការងារកម្មករកម្ពុជា**


ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារៈ ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh◆ Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org◆ Website: www.arbitrationcouncil.org

- សហព័ន្ធសហជីពសហប្រតិបត្តិការដើម្បីកម្ពុជា
- សហព័ន្ធសហជីពស្មារតីកម្មករកម្ពុជា
- សហព័ន្ធសហជីពអំណាចកម្មករខ្មែរ
- សហព័ន្ធសហជីពស្ថាបនាសិទ្ធិកម្មករ
- សហព័ន្ធសហជីពដើម្បីកម្មករ
- សហព័ន្ធសហជីពសម្លេងយុវជនខ្មែរ
- សហព័ន្ធសហជីពឯករាជ្យ និងប្រជាធិបតេយ្យ
- សហព័ន្ធសហជីពអភិវឌ្ឍន៍កម្មករ
- សហព័ន្ធសហជីពសម្ព័ន្ធកម្មករខ្មែរ
- សហព័ន្ធសហជីពលើកតម្កើងជីវភាពកម្មករនិយោជិតខ្មែរ

អាសយដ្ឋាន ៖ ផ្លូវជាតិលេខ៣ សួនឧស្សាហកម្មវឌ្ឍនៈ២ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៩២ ៨០០ ៩៦៣ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតចូលរួមផ្តល់ព័តមានលំអិត ៖

| | | |
|---|---|---|
| ១- | លោក ឈិន សូនី | ប្រធានសហព័ន្ធសហជីពការងារសេវាកម្មកម្ពុជា |
| ២- | លោក អ៊ុន នេត | ប្រធានសហព័ន្ធសហជីពការងារកម្មករសំណង់កម្ពុជា |
| ៣- | លោក អ៊ុន ដារ៉ា | ប្រធានសហព័ន្ធសហជីពស្មារតីកម្មករឯករាជ្យ |
| ៤- | លោក ស៊ុំ រ៉ង | ប្រធានសហព័ន្ធសហជីពសុវត្ថិភាពកម្មករ |
| ៥- | លោក ឃិន ណាំហោ | អនុប្រធានសហព័ន្ធសហជីពអភិវឌ្ឍន៍សិទ្ធិការងារ |
| ៦- | លោក ប៊ុន វណ្ណៈ | ប្រធានសហព័ន្ធសហជីពការងារកូនខ្មែរ |
| ៧- | លោក ហៀក បូរី | អគ្គលេខាធិការសហព័ន្ធសហជីពការងារកម្មករកម្ពុជា |
| ៨- | លោក អ៊ូ សុខហេង | ប្រធានសហព័ន្ធសហជីពសហប្រតិបត្តិការដើម្បីកម្ពុជា |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតទាមទារសុំឱ្យក្រុមហ៊ុនទទួលយកថ្នាក់ដឹកនាំ និងសកម្មជនសហជីពការងារកម្ពុជា ដើម្បីអភិវឌ្ឍន៍ ចូលធ្វើការវិញ ដោយរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗនៅដដែល ដែលមានឈ្មោះ មុំ សុខមាន, ណុប ផល្លី, ខឹម ប៊ុនធឿន, សាយ វ៉ាន់តូ, សាត់ ដេត, ញឹម ឧត្តម, យ៉ន មេត្តា, សំ ចាន់ធី, មាស សិត, ប្រាក់ ម៉ី, និង ជឹម ចាន់លន់។

២- កម្មករនិយោជិតទាមទារសុំឱ្យក្រុមហ៊ុនដករដ្ឋបាលឈ្មោះ រុកគី ឆាយ ចេញពីរោងចក្រ ព្រោះគាត់បានរើសសអើង និងគំរាមកំហែងសហជីព។

៣- ក្រុមហ៊ុនត្រូវទទួលស្គាល់សហជីពការងារកម្ពុជាដើម្បីអភិវឌ្ឍន៍ ប្រចាំក្រុមហ៊ុន ដុងខូ ថេកស្តាយ ។

៤- ស្នើសុំប្រាក់ថ្លៃបាយបន្ថែមម៉ោង ពីម៉ោង ១៦ ដល់ ១៨ ល្ងាច ចំនួន ៤០០០ រៀល ។

៥- សុំក្រុមហ៊ុនសាងសង់រោងបាយនៅអគារថ្មី (អគារ ១៧) ។

៦- ក្រុមហ៊ុនត្រូវបញ្ឈប់បុគ្គលិកណាដែលជេរប្រមាថ បង្ខិតបង្ខំ និងមើលងាយកម្មករនិយោជិត ។

៧- សុំឱ្យក្រុមហ៊ុនដាក់ធុងទឹកក្តៅទឹកត្រជាក់សម្រាប់កម្មករនិយោជិតផឹក ។

៨- ក្រុមហ៊ុនត្រូវសាងសង់ទារកដ្ឋានសម្រាប់ដាក់ក្មេង ។

៩- សុំឱ្យក្រុមហ៊ុនធ្វើកិច្ចសន្យាការងាររយៈពេលវែងសម្រាប់កម្មករនិយោជិត (យ៉ាងតិចរយៈពេល ៦ ខែ) ។

១០- សុំក្រុមហ៊ុនរៀបចំឱ្យមានរថយន្តសម្រាប់ដឹកកម្មករទៅមន្ទីរពេទ្យទាន់ពេលវេលា នៅពេលកម្មករឈឺធ្ងន់ ឬសន្លប់ក្នុងរោងចក្រ ។

១១- ក្រុមហ៊ុនត្រូវដោះស្រាយចំពោះតៃកុងឡានលេខ ៩ ដែលមានកំហុសមិនដឹកកម្មករ កាលពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៤ នៅមុខខ្លោងទ្វារសួន ។

១២- សុំឱ្យក្រុមហ៊ុនកាត់បន្ថយការកំណត់ចំនួនឱ្យកម្មករធ្វើហួសកំលាំង និងលទ្ធភាព ។

១៣- សុំក្រុមហ៊ុនបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតបានទៀងទាត់ យូរបំផុតត្រឹមថ្ងៃទី៧ ខែមករា ឆ្នាំ ២០១៤ ។

១៤- សុំឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ នៅពេញដដែល ជូនកម្មករនិយោជិត ក្នុងអំឡុងពេលធ្វើកូដកម្ម ។

១៥- សុំឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យស្ត្រីដែលសម្រាលកូនរួច បានចេញបំបៅដោះកូនមួយម៉ោងក្នុងមួយថ្ងៃ ។

១៦- សុំឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យស្ត្រីមានផ្ទៃពោះចេញមុនម៉ោង ២០ នាទី ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩៥ កប/ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (អាណត្តិទី១១) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជាមួយគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១២២ កប/អក/វក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ ។

THE ARBITRATION COUNCIL

**សវនាការ និង សង្ខេបនីតិវិធី**

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ" ។

**កាលបរិច្ឆេទកិច្ចប្រជុំមុនសវនាការ** ៖ - ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៤ (វេលាម៉ោង ១៣ និង ៣០ នាទី រសៀល)។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្ដឹងពីនិយោជក ស្ដីពីកម្មករនិយោជិតធ្វើកូដកម្ម ទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលពាក្យបណ្ដឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះ ជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ ទៅលើការទាមទារសរុបចំនួន ១៦ ចំណុច។ ចំណុចមិនសះជាទាំង ១៦ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ តាមរយៈរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ដុងខូ ថេកស្ទាយ លេខ ១២២ កប/អក/វក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានទទួលព័ត៌មានថា កូដកម្មនៅតែបន្ត បន្ទាប់ពីសំណុំរឿងត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាល។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានទទួលលិខិតមួយច្បាប់របស់ក្រុមហ៊ុន ដុងខូ ថេកស្ទាយ (ខេមបូឌា) ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ ស្ដីពីសំណើសុំចេញសេចក្ដីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិត ដែលបានចាប់ផ្ដើមពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៤ មក។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចេញសេចក្ដីបញ្ជា លេខ ០០៥/១៤ កបអ. ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ឱ្យកូដករផ្អាកជាបន្ទាន់នូវការធ្វើកូដកម្មនៅក្រុមហ៊ុន ដុងខូ ថេកស្ទាយ (ខេមបូឌា) រហូតដល់នីតិវិធីនៃអាជ្ញាកណ្ដាលត្រូវបានចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីព្រឹកថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៤ តទៅ តាមវេនរបស់ខ្លួន។ យ៉ាងណាមិញ ក្រោយការចេញសេចក្ដីបញ្ជានេះ កូដករនៅតែបន្តធ្វើកូដកម្មដដែល ដោយកូដករមិនបានគោរពតាមសេចក្ដីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនេះទេ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានអញ្ជើញភាគីទាំងពីរមកសាកសួរព័ត៌មានបន្ថែម អំពីស្ថានភាពនៃការធ្វើកូដកម្មនេះ ក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្ដាល នាថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៤ វេលាម៉ោង ១៣៖៣០ នាទី រសៀល។ ភាគីទាំងពីរមានវត្តមាន តាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ហើយភាគីទាំងពីរបានទទួលស្គាល់ដូចគ្នាថា កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងធ្វើការពិចារណា និងសម្រេចដូចខាងក្រោម៖

**គស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖គ្មាន**

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ របស់ក្រុមហ៊ុន ដុងខូ ថេកស្ទាយ (ខេមបូឌា) គោរពជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំចេញសេចក្តីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្ម របស់កម្មករនិយោជិត នៅក្រុមហ៊ុន ដុងខូ ថេកស្ទាយ (ខេមបូឌា) ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ដុងខូ ថេកស្ទាយ (ខេមបូឌា) លេខ ១២២ កប/អក/វក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ដុង ខូ ថេកស្ទាយ (ខេមបូឌា) ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ជម្រាបមក លោកប្រធានសហព័ន្ធសហជីពទាំង ១៧ ស្តីពីការជ្រើសរើសអាជ្ញាកណ្តាល លេខ ១២៣ កប/អក/វក/លកអ. ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤។

២- កំណត់ហេតុស្តីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាល ពីបញ្ជីឈ្មោះអាជ្ញាកណ្តាលស្នើដោយសហជីពកម្មករនិយោជិត ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤។

៣- សេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០០៥/១៤ កបអ. ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤។

៤- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័តមានលំអិត លេខ ១៣៨ កប/អក/វក/លកអ. ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៤។

៥- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួម ផ្តល់ព័តមានលំអិត លេខ ១៣៧ កប/អក/វក/លកអ. ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៤។

**អង្គហេតុ ៖**

- មិនមានការរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជា ដែលនាយកដ្ឋានវិវាទការងារបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានដំណើរការសវនាការ ។

THE ARBITRATION COUNCIL

**ហេតុផលនៃសេចក្ដីសម្រេច ÷**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិចារណាថា តើត្រូវបន្តនីតិវិធីអាជ្ញាកណ្ដាលដែរ ឬទេ?

ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ចែងថា៖ *“ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្ដាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្ដីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយដែលក្រុមអាជ្ញាកណ្ដាលបានអញ្ជើញឱ្យចូលរួម ”*។

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ភាគីវិវាទត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ នៅក្នុងដំណើរការអាជ្ញាកណ្ដាល។

នៅក្នុងសេចក្ដីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងមិនបន្តដំណើរការអាជ្ញាកណ្ដាលទេ នៅពេលណាភាគីកម្មករនិយោជិត កំពុងធ្វើកូដកម្ម ឬនិយោជកធ្វើឡុកអៅ។ (សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ *៥៩/០៦-សាង វ៉ូ, លេខ ៣៥/០៨-ចុង យ៉ូវ, លេខ ១៣៧/០៩, ១៣៨/០៩-ញ៉ូ ភាញ់, លេខ ១១០/១១-ស៊ីម៉ាញូ, លេខ ១០៤/១៣-សាប្រ៊ីណា (ខេមបូឌា) និងលេខ ១១៩/១៣-ពូយៀន)*។

ឧទាហរណ៍ នៅក្នុងសំណុំរឿងលេខ ០៤/០៤-អិម អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចេញសេចក្ដីជូនដំណឹងមួយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខ័ណ្ឌទី៤ នៃសេចក្ដីជូនដំណឹងនេះ កំណត់ថា ៖

*“ ដោយពិនិត្យឃើញថា ភាគីនៃវិវាទការងារនេះមិនមានសិទ្ធិធ្វើកូដកម្ម ក្នុងកំឡុងពេលនៃដំណើរការរបស់អាជ្ញាកណ្ដាល ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្ដីបង្គាប់លើវិវាទការងាររួមនេះ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាលឡើយ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលអាចដោះស្រាយវិវាទការងាររួមនេះម្ដងទៀតបាន នៅពេលណាដែលសហជីពកម្មករនិយោជិតទាំងអស់ឈប់ធ្វើកូដកម្ម ”*។

ដូចគ្នាដែរ នៅក្នុងសំណុំរឿងលេខ ១៨/០៤-សណ្ឋាគារ (កាំបូឌីយ៉ាណា, ក៉ាហ្វេល ឡឺរ៉ូយ៉ាល់, ក៉ាហ្វេល ប្រែ្កនឌិ អង្គរ, សាន់វេ, អ៊ិនធើខនធីណេនថល និងសូហ្វីតែល អង្គរ) ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចេញសេចក្ដីបញ្ជាទីពីរ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៤ ដែលចំណុចទី៩ និងទី១១ នៃសេចក្ដីបញ្ជានេះ ចែងដូចខាងក្រោម ៖

*“ ចំណុចទី៩- ចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ តទៅ កម្មករនិយោជិតទាំងអស់ត្រូវបញ្ឈប់កូដកម្ម បាតុកម្ម ឬការរំខានណាមួយ នៅក្នុងបរិវេណសណ្ឋាគារនានា ដែលជាភាគីនៃវិវាទនេះ ”*។

*“ ចំណុចទី ១១-ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរក្សាសិទ្ធិក្នុងការបញ្ចប់ដំណើរការអាជ្ញាកណ្ដាល ករណីដែលភាគីណាមួយបំពានប្រការណាមួយនៃសេចក្ដីបញ្ជានេះ ”*។

នៅក្នុងសំណុំរឿងលេខ ៧៧/០៥-ហ្វ្រង់កូ នីតធីង ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចេញសេចក្ដីបញ្ជាទី២ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៥ ហើយបានចែងនៅក្នុងចំណុចទី៤ ថា នៅក្នុងករណីដែលភាគីកម្មករនិយោជិតបន្តធ្វើ

ARBITRATION COUNCIL

កូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនដំណើរការដោះស្រាយវិវាទការងាររួមនេះទេ។

នៅក្នុងសំណុំរឿងលេខ ១១០/១១-ស៊ីម៉ាណូ និងសំណុំរឿងលេខ ១៧/១៣-អ៊ិនធើណាស្យូណាល់ ហ្វេសិន វ៉ូយ៉ាល់ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានចេញសេចក្តីបង្គាប់មិនបន្តដំណើរការអាជ្ញាកណ្តាល ដោយមូលហេតុ កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម ក្នុងអំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែរ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របតាមការសម្រេច របស់ក្រុមប្រឹក្សាអាជ្ញា-កណ្តាលក្នុងសំណុំរឿងខាងលើដែរ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកោះហៅភាគីទាំងពីរមកបំភ្លឺលើករណីកូដកម្មនេះ នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ ២០១៤ វេលាម៉ោង ១៣៖៣០ នាទី រសៀល។ ភាគីទាំងពីរមានវត្តមាន តាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងបានទទួលស្គាល់ដូចគ្នាថា កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម ដោយមិនគោរពតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ឡើយ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងនេះ។

យោងតាមអង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

- បញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ០១៩/១៤-ដុងឌូ ថេកស្តាយ (ខេមបូឌា)។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត

ឈ្មោះ ៖ **លឹម សុវណ្ណា**

ហត្ថលេខា ៖ ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល

ឈ្មោះ ៖ **ម៉ែន ប៊ុនណា**

ហត្ថលេខា ៖ ------------------------------

THE ARBITRATION COUNCIL